អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១០

# អង្គភាពគាំពារជនរងគ្រោះរៀបចំវេទិកាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងក្រុងបាត់ដំបង

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) នាថ្ងៃនេះបានរៀបចំវេទិកា ដែលមានរយៈពេលពីរថ្ងៃក្នុងក្រុងបាត់ដំបង សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២៥០នាក់ ក្នុងសំណុំរឿង០០២។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះមកពីខេត្តបាត់ដំបង បន្ទាយមានជ័យ និងពោធិ៍សាត់។

វេទិកានេះផ្ដល់ឱកាសឲ្យដើមបណ្ដឹងរដ្ឋប្បវេណីសិក្សាអំពីការវិវឌ្ឍថ្មីៗនៅតុលាការ និងការរីកចម្រើនក្នុងករណីផ្ទាល់ខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ។ វេទិកានេះក៏ផ្ដល់ឱកាសផងដែរដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការជួបមេធាវីរបស់ខ្លួន និងពិភាក្សាអំពីការចូលរួមរបស់ខ្លួនក្នុងសំណុំរឿង០០២ និងការរំពឹងទុករបស់ខ្លួន។

ក្នុងឱកាសបើកវេទិកា ឯកឧត្ដម ក្រាញ់ តូនី ប្រធានស្ដីទីនៃការិយាល័យរដ្ឋបាលនៃអវតក បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ឯកឧត្ដមមានប្រសាសន៍ថា “នេះគឺជាលើកដំបូងក្នុងតុលាការ ដែលគាំទ្រដោយសហគមន៍អន្តរជាតិ ដែលជនរងគ្រោះមានសិទ្ធិពេញលេញក្នុងការចូលរួម ក្នុងនាមជាភាគីក្នុងដំណើរការនីតិវិធី”។ ឯកឧត្ដមបញ្ជាក់ថា គោលបំណងចម្បងនៃការិយាល័យរដ្ឋបាលគឺគាំទ្រដល់ការអនុវត្តដ៏មានប្រសិទ្ធភាពនៃសិទ្ធិរបស់ភាគីនៅចំពោះមុខតុលាការ។ ឯកឧត្ដម ក្រាញ់ តូនី បានឆ្លៀតឱកាសនេះប្រគល់ជូនសៀវភៅសាលក្រមក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ដល់លោកនៅ យ៉ារ័ត្ន ប្រធានតុលាការខេត្តបាត់ដំបង ដើម្បីទុកជាឯកសារយោងសម្រាប់ចៅក្រមនៅតុលាការខេត្ត។ លោក នៅ យ៉ារ័ត្ន បានប្រកាសថា ខ្លួនលោកផ្ទាល់ “ពេញចិត្តយ៉ាងខ្លាំង” នឹងសាលក្រមប្រឆាំងនឹង កាំង ហ្គេកអ៊ាវ។

ឯកឧត្ដម សៀង ស៊ិតថង អភិបាលរងខេត្តបាត់ដំបង ក៏បានកត់សម្គាល់ផងដែរអំពីសារៈសំខាន់នៃដំណើរការនីតិវិធី ដែលអនុញ្ញាតឲ្យជនរងគ្រោះបន្តកសាងជីវិតរបស់ខ្លួនក្នុងសហគមន៍ ហើយឯកឧត្ដមបានថ្លែងអំណរគុណដល់តុលាការក្នុងការរៀបចំវេទិកាដើមបណ្ដឹងរដ្ឋប្បវេណីលើកទីមួយនេះក្នុងភូមិភាគនេះ។

វេទិកានេះប្រព្រឹត្តទៅនៅថ្ងៃទី៣០ និង៣១ ខែសីហា និងបានចូលរួមផងដែរដោយអង្គការសង្គមស៊ីវិល ដែលជួយដល់ជនរងគ្រោះក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងពាក្យបណ្ដឹង។